ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែដែនជម្រកសត្វព្រៃភ្នំណាមលៀរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សម្រេច**

**មាត្រា១ .-**

ត្រូវបានកែប្រែដែនជម្រកសត្វព្រៃភ្នំណាមលៀរ ពីផ្ទៃដីទំហំ៤៧ ៥០០(បួនម៉ឺនប្រាំពីរពាន់ប្រាំរយ) ហិកតា មកផ្ទៃដីទំហំ៦៤ ៨៣៥(ប្រាំមួយម៉ឺនបួនពាន់ប្រាំបីរយសាបសិបប្រាំ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមការ(តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum WGS.1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីដែនជម្រកសត្វព្រៃភ្នំណាមលៀរខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ៤៧ ៥០០(បួនម៉ឺនប្រាំពីរពាន់ប្រាំរយ)ហិកតា ដែលមានចែងក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះញៀសាន ដែលមានផ្ទៃដីទំហំ១៧ ៣៣៥(មួយម៉ឺនប្រាំពីរពាន់បីរយសាមសិបប្រាំ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ ប្រព័ន្ធអេកូឡូស៊ី និងសារព័នមជ្ឈដ្ឋានធម្មជាតិ ដោយមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តមណ្ឌលគិរី ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣
ផែនទីដែនជម្រកសត្វព្រៃភ្នំណាមលៀវ ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី
ខេត្តមណ្ឌលគិរី
750000
760000
770000
780000
790000
1410000
1400000
1390000
1380000
1370000
1360000
1350000
ដែនជម្រកសត្វព្រៃភ្នំណាមលៀវ
សញ្ញាសម្គាល់
ចំណុចនិយាមកា
ព្រំប្រទល់ប្រទេស
ព្រំប្រទល់តំបន់ការពារធម្មជាតិ
មាត្រដ្ឋាន 1:200,000
0 5 10 km
Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
ប្រភពទិន្នន័យ
: Google Earth

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៧៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣**

**ចំណុចនិយាមកានៃផែនទីដែនជម្រកសត្វព្រៃភ្នំណាមលៀរ**

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 776685 | 1403848 | 26 | 766086 | 1383317 | 51 | 759695 | 1379759 |
| 2 | 774395 | 1402336 | 27 | 765785 | 1381885 | 52 | 759858 | 1377854 |
| 3 | 772079 | 1401673 | 28 | 766745 | 1380144 | 53 | 760501 | 1376043 |
| 4 | 768255 | 1401658 | 29 | 767818 | 1378606 | 54 | 759968 | 1374138 |
| 5 | 764372 | 1401650 | 30 | 768491 | 1376433 | 55 | 758633 | 1372969 |
| 6 | 760924 | 1401642 | 31 | 767268 | 1376556 | 56 | 759468 | 1371098 |
| 7 | 760326 | 1400274 | 32 | 766537 | 1377824 | 57 | 758479 | 1369698 |
| 8 | 760353 | 1399117 | 33 | 765779 | 1376993 | 58 | 757357 | 1368670 |
| 9 | 760310 | 1397632 | 34 | 766156 | 1378237 | 59 | 757181 | 1366718 |
| 10 | 759000 | 1397423 | 35 | 764476 | 1378324 | 60 | 755008 | 1366063 |
| 11 | 758325 | 1395800 | 36 | 762589 | 1376924 | 61 | 754881 | 1364531 |
| 12 | 759585 | 1394297 | 37 | 761581 | 1378324 | 62 | 756162 | 1363223 |
| 13 | 760929 | 1393906 | 38 | 761583 | 1379917 | 63 | 757866 | 1361938 |
| 14 | 762305 | 1393345 | 39 | 761585 | 1381889 | 64 | 759081 | 1360122 |
| 15 | 764506 | 1393715 | 40 | 761587 | 1383861 | 65 | 759630 | 1357793 |
| 16 | 767176 | 1394124 | 41 | 761589 | 1385472 | 66 | 760972 | 1356492 |
| 17 | 767010 | 1392503 | 42 | 761573 | 1387322 | 67 | 776051 | 1372285 |
| 18 | 767209 | 1391122 | 43 | 760125 | 1387338 | 68 | 772927 | 1372324 |
| 19 | 769188 | 1391104 | 44 | 758689 | 1387338 | 69 | 772921 | 1375251 |
| 20 | 769189 | 1389165 | 45 | 757714 | 1386658 | 70 | 772915 | 1377903 |
| 21 | 770254 | 1389175 | 46 | 758342 | 1385473 | 71 | 772919 | 1380315 |
| 22 | 770249 | 1386664 | 47 | 759354 | 1384869 | 72 | 773581 | 1380324 |
| 23 | 770244 | 1384321 | 48 | 759427 | 1384051 | 73 | 773581 | 1382308 |
| 24 | 769594 | 1383348 | 49 | 758995 | 1382805 | 74 | 776846 | 1382291 |
| 25 | 767811 | 1383332 | 50 | 760039 | 1381291 | 75 | 779689 | 1382276 |